# ជំពូកទី5 ការប្រឹក្សាពិគ្រោះយោបល់សាធារណៈ

ការអភិវឌ្ឍន៍គំពេងនៅតំបន់មួយ អាចបណ្តាលឲ្យមានផលប៉ះពាល់មួយចំនួនទៅលើប្រជាពលរដ្ឋដែលរស់នៅក្បែរ ឬឆ្ងាយពីតំបន់នោះ។ អាស្រ័យហេតុនេះ វាជាការចាំបាច់ដែលត្រូវផ្សព្វផ្សាយព័ត៌មាននេះ ដល់អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ។ ម៉្យាងវិញទៀត ការបង្កើតជាការប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ គឺជាការសំខាន់ផងដែរ ដើម្បីទទួលបាននូវមតិរិះគន់ យោបល់គាំទ្រ ព័ត៌មានលំអិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ និងអនុសាសន៍នានា សម្រាប់ជាទុនក្នុងការវាយតំលៃគំពេង ថាតើគំពេងនេះពិតជាការអភិវឌ្ឍន៍មែន ឬមិនមែន ព្រមទាំងអាចបញ្ជាក់ឲ្យដឹងផងដែរថាតើប្រជាពលរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធនៅតំបន់នេះ ពិតជាស្វាគមន៍ក្នុងការឲ្យមានគំពេងនេះនៅតំបន់រស់នៅរបស់គាត់ដែរឬទេ។

នៅក្នុងផ្នែកនេះ គឺជាផ្នែកមួយដ៏សំខាន់ដែលក្រុមហ៊ុនត្រូវផ្សព្វផ្សាយអំពីវត្តមានរបស់គំពេង ដើម្បីឲ្យប្រជាជន អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងអង្គការពាក់ព័ន្ធផ្សេងៗជ្រាបអំពីកិច្ចដំណើរការរបស់គំពេង ដែលនឹងមានវត្តមាននៅក្នុងទឹកដីរបស់ពួកគាត់។

ក្នុងកិច្ចដំណើរការពិគ្រោះយោបល់នេះ គឺធ្វើឡើងនៅក្នុងដំណាក់កាលដំបូងមុននឹងគំពេងចាប់ផ្តើមដំណើរការបូមល្បាប់ខ្សាច់ដើម្បីបង្កើតឃ្លងនាវាចេញ-ចូល សំដៅទទួលយកនូវការផ្តល់មតិយោបល់ និងអនុសាសន៍ល្អៗពីគ្រប់អ្នកពាក់ព័ន្ធ(Stakeholders) ដើម្បីក្រុមហ៊ុនទទួលយកមកអនុវត្តឲ្យបានរលូន និងប្រកបដោយភាពជោគជ័យ។

## 5.1-វិធីសាស្ត្រ

សកម្មភាពនៃកិច្ចដំណើរការពិគ្រោះយោបល់នេះ ក្រុមការងារបានរៀបចំជាពីរវគ្គដាច់ដោយឡែកពីគ្នាគឺ ៖ លើកទី1 មានការរៀបចំជ្រើសរើសប្រជាពលរដ្ឋចំនួន 215គ្រួសារ ជាភូមិគោលដៅក្នុងឃុំបឹងទូក ឃុំកោះតូច និងឃុំព្រែកត្នោត មកធ្វើការសម្ភាសន៍ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី27 ខែកុម្ភៈ ដល់ថ្ងៃទី03 ខែមីនា ឆ្នាំ2010 ដើម្បីស្ទង់មតិជាមួយប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធទៅនឹងគំពេង និងលើកទី2 មានការរៀបចំកិច្ចដំណើរការពិគ្រោះយោបល់ជាសាធារណៈគឺចាប់ពីថ្ងៃទី29 ខែមេសា ឆ្នាំ2010 ដល់ថ្ងៃទី03 ខែឧសភា ឆ្នាំ2010 ដោយមានមន្ត្រីនាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានចំនួន03រូប ចូលរួមអង្កេតការ តាមរយៈលិខិតលេខ 053 លចប.បស្ថ ចុះថ្ងៃទី11 ខែ កុម្ភៈ ឆ្នាំ2010 ផងដែរ។

## 5.2-គោលបំណងនៃការពិគ្រោះយោបល់

ការពិគ្រោះយោបល់ជាសាធារណៈនេះមានគោលបំណង៖

-ផ្សព្វផ្សាយអំពីគោលបំណង និងផែនការអភិវឌ្ឍន៍របស់គំពេង ឲ្យបានជ្រាបដល់សាធារណៈជន និងអ្នកដែលពាក់ព័ន្ធទៅនឹងគំពេង

-ផ្តល់ឱកាសឲ្យអ្នកពាក់ព័ន្ធបានបញ្ចេញនូវមតិយោបល់ និងសំណូមពរ

-ដោះស្រាយសំណូមពររបស់អ្នកពាក់ព័ន្ធ ។

## 5.3-លទ្ធផលនៃការពិគ្រោះយោបល់

### 5.3.1-ការស្ទង់មតិជាមួយប្រជាពលរដ្ឋមូលដ្ឋាន

យោងតាមការស្ទង់មតិរបស់ក្រុមការងារCES ទៅលើប្រជាពលរដ្ឋចំនួន215គ្រួសារ ជាភូមិគោលដៅទាំង9 នៃឃុំទាំង3ក្នុងនោះរួមមាន (មានបង្ហាញលំអិតនៅក្នុងជំពូកទី3) ៖

(1)-ឃុំបឹងទូក៖ ភូមិរលួស

(2)-ឃុំកោះតូច៖ ភូមិគីឡូ12 ភូមិព្រែកចេក ភូមិកណ្ដាល និងភូមិព្រែកអំពិល

(3)-ឃុំព្រែកត្នោត៖ ភូមិចង្ហោន ភូមិព្រែកត្នោត ភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ

មកធ្វើការសម្ភាសន៍ ជាលទ្ធផលនៃការស្ទង់មតិទៅលើគំរោងបូមល្បាប់ខ្សាច់ដើម្បីបង្កើតឃ្លងនាវាចេញ-ចូល និងការចាក់ ដីបំពេញនៅទីតាំងតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត របស់ក្រុមហ៊ុន KAMPORT PORT ។ នេះបាន បង្ហាញថា(តារាង 5.1) ប្រជាពលរដ្ឋភូមិរលួស ឃុំបឹងទូក ចំនួន27នាក់ ដែលក្រុមការងារCESបានស្ទង់មតិ ក្នុងនោះ មានចំនួន81% បានយល់ព្រមឲ្យក្រុមហ៊ុនKAMPORT PORT ធ្វើការអភិវឌ្ឍន៍ មានចំនួន15% មិនយល់ព្រមឲ្យធ្វើការ អភិវឌ្ឍន៍ និង4% មិនមានយោបល់។

-ប្រជាពលរដ្ឋភូមិគីឡូ12 ភូមិព្រែកចេក ភូមិកណ្ដាល និងភូមិព្រែកអំពិល ឃុំកោះតូច ចំនួន94នាក់ ដែល ក្រុម ការងារCES បានស្ទង់មតិ ក្នុងនោះមានចំនួន86% បានយល់ព្រមឲ្យក្រុមហ៊ុនKAMPORT PORT។ ធ្វើការអភិវឌ្ឍន៍ មាន ចំនួន6% មិនយល់ព្រមឲ្យធ្វើការអភិវឌ្ឍន៍ និង8% មិនមានយោបល់។

-ប្រជាពលរដ្ឋភូមិចង្ហោន ភូមិព្រែកត្នោត ភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ ឃុំព្រែកត្នោត ចំនួន94នាក់ ដែល ក្រុមការងារCES បានស្ទង់មតិ ក្នុងនោះមានចំនួន78% បានយល់ព្រមឲ្យក្រុមហ៊ុនKAMPORT PORT។ ធ្វើការអភិវឌ្ឍន៍ មានចំនួន13% មិនយល់ព្រមឲ្យធ្វើការអភិវឌ្ឍន៍ និង9% មិនមាន យោបល់។

-លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋចំនួន215នាក់ ដែលបានផ្ដល់សម្ភាសន៍មានការគាំទ្រលើគំរោង អភិវឌ្ឍន៍ចំនួន176នាក់ ស្មើនឹង82% មិនគាំទ្រលើគំរោងអភិវឌ្ឍន៍ចំនួន22នាក់ ស្មើនឹង10% និងមិនមានយោបល់ ក្នុង ការផ្ដល់សម្ភាសន៍មានចំនួន17នាក់ ស្មើនឹង8%។

ជារួមប្រជាពលរដ្ឋបានសំណូមពរ ៖

-ស្នើសុំឲ្យក្រុមហ៊ុនផ្ដល់លទ្ធភាពដល់ពួកគាត់ឲ្យចូលបំរើការងារក្នុងគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន

-ជួយអភិវឌ្ឍន៍ភូមិ-ឃុំរបស់ពួកគាត់ ដែលក្នុងនោះមានទឹកស្អាត អគ្គិសនី ផ្លូវថ្នល់ សាលារៀន

-ជួយធ្វើទំនប់ទប់ទឹកប្រៃកុំឲ្យទឹកសមុទ្រចូលដីស្រែរបស់ពួកគាត់

-ស្នើសុំឲ្យក្រុមហ៊ុនជួយស្តារប្រឡាយឲ្យបានជ្រៅ និងធំបន្តិច ដើម្បីផ្ដល់ភាពងាយស្រួលដល់ការចតទូក

-ទុកផ្លូវទឹកឲ្យប្រជាជនចេញទៅធ្វើការនេសាទ

-សុំឲ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍ឲ្យបានឆាប់រហ័ស

-សុំកុំឲ្យក្រុមហ៊ុនបូមល្បាប់ខ្សាច់បង្កើតឃ្លងនាវាចេញ-ចូលប៉ះពាល់ដល់ការដាំសារាយ ការនេសាទ និងដែន សហគមន៍របស់ពួកគាត់

-ស្នើសុំឲ្យក្រុមហ៊ុនបូមល្បាប់ខ្សាច់ដោយអនុវត្តទៅតាមផែនការឲ្យបានច្បាស់លាស់។

តារាង 5.1 តារាងស្តីពីការស្ទង់មតិលើប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធនឹងគំរោងអភិវឌ្ឍន៍

| ឈ្មោះឃុំ | ចំនួនប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ | ការស្ទង់មតិលើប្រជាពលរដ្ឋ | | | | | |
|---|---|---|---|---|---|---|---|
| | | យល់ព្រម | | មិនយល់ព្រម | | អនុប្រវាទ | |
| | | ចំនួនមនុស្ស | ភាគរយ | ចំនួនមនុស្ស | ភាគរយ | ចំនួនមនុស្ស | ភាគរយ |
| ឃុំបឹងទូក | 27នាក់ | 22នាក់ | 81 | 04នាក់ | 15 | 01នាក់ | 04 |
| ឃុំកោះតូច | 94នាក់ | 81នាក់ | 86 | 06នាក់ | 06 | 07នាក់ | 08 |
| ឃុំព្រែកត្នោត | 94នាក់ | 73នាក់ | 78 | 12នាក់ | 13 | 09នាក់ | 09 |
| សរុបៈ | 215នាក់ | 176នាក់ | 82 | 22នាក់ | 10 | 17នាក់ | 08 |

### 5.3.2 ការពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ

ការពិគ្រោះយោបល់នេះបានប្រព្រឹត្តទៅនៅថ្ងៃទី30 ខែមេសា ឆ្នាំ2010 វេលាម៉ោង03រសៀល នៅសាលប្រជុំសាលាខេត្តកំពត ដែលកិច្ចពិភាក្សាពិគ្រោះយោបល់នេះស្ថិតក្រោមអធិបតីភាពលោក ស៊ុក សារ៉ាង នាយខុទ្ទកាល័យសាលាខេត្តកំពត តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអភិបាលខេត្តកំពត។

ស្ថាប័នដែលពាក់ព័ន្ធចូលរួមពិភាក្សាពិគ្រោះយោបល់មានៈ

-ក្រសួងបរិស្ថាន (អ្នកអង្កេតការ)
-មន្ទីរបរិស្ថានខេត្តកំពត
-ខណ្ឌរដ្ឋបាលជលផល ប្រចាំខេត្តកំពត
-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពត
-មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត
-មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តកំពត
-អាជ្ញាធរស្រុកទឹកឈូ
-អាជ្ញាធរឃុំបឹងទូក
-អាជ្ញាធរឃុំកោះតូច
-អាជ្ញាធរឃុំព្រែកត្នោត
-ក្រុមហ៊ុន KAMPORT POT និង
-ក្រុមហ៊ុន CES

នៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់នេះ លោក សុខ សុធា ប្រធានក្រុមការងាររបស់ក្រុមហ៊ុន CES ដែលជាអ្នកសិក្សានិងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានធ្វើបទបង្ហាញជូនអង្គប្រជុំជ្រាបអំពីលទ្ធផល ដែលក្រុមហ៊ុន CES បានសិក្សានាពេលកន្លងមក បន្ទាប់មកអង្គប្រជុំបានពិភាក្សា និងផ្តល់ដោយមានខ្លឹមសារដូចខាងក្រោមៈ

- លោក ឈូក ផូ មេឃុំកោះតូច ៖ លោកបានលើកឡើងថា គំរោងអភិវឌ្ឍន៍នេះមានការពាក់ព័ន្ធភូមិចំនួន4 នៃឃុំកោះតូច ក្នុងនោះភូមិគីឡូ12 ទទួលរងការប៉ះពាល់ផ្ទាល់ដោយការចាក់ដីលុបបំពេញទីតាំងតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត។ កាលពីមុននៅជំហានដំបូងមានប្រជាជននៅភូមិគីឡូ12នេះ ប្រមាណ50-60គ្រួសារ ជំទាស់លើការអភិវឌ្ឍន៍នេះ ប៉ុន្តែបន្ទាប់ពីក្រុមហ៊ុនមានការសំរបសំរួលជាមួយប្រជាជនទាំងនោះ ប្រជាជនក៏ស្ងប់ស្ងាត់ទៅវិញ។ បច្ចុប្បន្នមានប្រជាជនមួយចំនួនបានចូលធ្វើការជាមួយក្រុមហ៊ុនផងដែរ។ ដោយឡែកប្រជាជន3ភូមិទៀត រួមមានៈ ភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល មិនជំទាស់លើគំរោង

Draft

អភិវឌ្ឍន៍នេះទេ។ ភូមិទាំង3នេះ កាលពីមុនមានប្រជាជនរាប់រយគ្រួសារបានប្រកបរបរដាំសារាយ ប៉ុន្តែដោយសារការដាំសារាយមានបញ្ហាដូចជា ពូជសារាយក្លាយ ត្រីស៊ីសារាយ និងទុនមិនគ្រប់គ្រាន់ បានធ្វើឲ្យប្រជាជនមួយចំនួនឈប់ដាំសារាយ ហើយបច្ចុប្បន្នមានប្រជានៅសល់តែប្រមាណ77គ្រួសារ ប៉ុណ្ណោះដែលបានដាំសារាយ ដោយក្នុង1គ្រួសារដាំពី50-100ខ្សែ (ប្រហែល 0,5ហិកតា)។ ក្នុងនាមអាជ្ញាធរឃុំកោះតូច ខ្ញុំសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះ ព្រោះដើម្បីឲ្យប្រជាជនមានការងារធ្វើ ស្របពេលដែលមុខរបរដាំសារាយ និងនេសាទកំពុងតែទទួលបានកំរៃទាប និងដើម្បី កាត់បន្ថយភាពក្រីក្រ។

- លោក ទូច ធឿង មេឃុំបឹងទូក ៖ លោកបានមានប្រសាសន៍ថា គំរោងអភិវឌ្ឍន៍នេះមានការប៉ះពាល់ដោយផ្ទាល់ទៅលើភូមិរលួស ដែលជាទីតាំងត្រូវចាក់ដីបំពេញ ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត ហើយការ ចាក់ដីនៅដំណាក់កាលដំបូង ប្រជានេសាទបានប្តឹងក្រុមហ៊ុនឲ្យផ្អាកសកម្មភាព ហើយពេលនោះអាជ្ញាធរឃុំបានចុះ អង្កេតឃើញថា ជាក់ស្តែងមានការញុះញង់ពីមជ្ឈដ្ឋានខាងក្រៅ ដោយឲ្យប្រជាជនផ្តិតមេដៃប្តឹងដើម្បីផល ប្រយោជន៍ផ្ទាល់ខ្លួន។ មកដល់ពេលនេះ ពុំមានអ្នកប្តឹងតវ៉ាទៀតទេ គឺមានតែអ្នកសំណូមពរឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ ឲ្យបានឆាប់រហ័ស ដើម្បីពួកគាត់បានចូលបំរើការងារក្នុងក្រុមហ៊ុន។ នៅឃុំបឹងទូកពុំមានប្រជាជនប្រកបរបរដាំសារាយទេ គឺមានតែអ្នកនេសាទ។ លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះទាំងស្រុង។
- លោក ជុន ទី ជំទប់ទី1 ឃុំព្រែកត្នោត ៖ លោកបានមានប្រសាសន៍ថា ឃុំព្រែកត្នោតពុំមានពាក់ព័ន្ធនឹងទីតាំងចាក់ខ្សាច់បំពេញទេ តែអាចពាក់ព័ន្ធដោយសារការបូមល្បាប់ខ្សាច់បង្កើតឃ្លងនាវាចេញ-ចូលពង់ផែ ដែលអាចធ្វើឲ្យប៉ះពាល់ទៅលើភូមិចំនួន4 របស់ឃុំព្រែកត្នោត គឺភូមិចង្ហោន ភូមិព្រែកត្នោត ភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ ដែលក្នុងនោះមានសហគមន៍នេសាទចំនួន3 នៅក្នុងភូមិទាំង4នេះផងដែរ។ តាមការបង្ហាញរបស់ក្រុមហ៊ុន CES ទីតាំងឃ្លងដែលត្រូវបូមមានចំងាយប្រមាណ 1គ.មតំបន់ជិតបំផុត ឬលើសពី4គ.ម ពីដែនសហគមន៍ ដូចនេះជាយោបល់ ខ្ញុំគឺមិនមានការប៉ះពាល់អ្វីទេ តែអាចប៉ះពាល់តិចតួចដោយសារការសាយភាយកករ ដូចក្រុមការងារ CES បានលើកឡើង។ លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះទាំងស្រុង។
- លោក ស សុទិន នាយខណ្ឌរដ្ឋបាលជលផលខេត្តកំពត ៖ លោកបានមានប្រសាសន៍ថា ឆ្លងតាមបទបង្ហាញរបស់ក្រុមការងារCES ឃើញថាមាន3ឃុំដែលនឹងត្រូវរងការប៉ះពាល់ គឺឃុំបឹងទូក ឃុំកោះតូច និងឃុំព្រែកត្នោត។ នៅតាមតំបន់ឆ្នេរនៃឃុំទាំង3នេះ មានសហគមន៍នេសាទចំនួន5 គឺសហគមន៍ភូមិទទឹងថ្ងៃ សហគមន៍ភូមិរលួស សហគមន៍ភូមិចង្ហោន សហគមន៍ព្រែកត្នោត និងសហគមន៍ព្រែកក្រែងនិងត្រពាំងរពៅ។ តំបន់អភិវឌ្ឍន៍នេះមានការប៉ះពាល់ដល់ស្មៅសមុទ្រប្រមាណជាង 1,000ហិកតា ដែលក្នុងនោះស្មៅសមុទ្រ 900 ហិកតា ត្រូវបានអភិរក្សដោយអង្គការ UNEP និង300ហិកតា ត្រូវបានពង្រីកបន្ថែមដែលអភិរក្សដោយ DANIDA នៅអំឡុងឆ្នាំ2009។ ឆ្នេរនៅតំបន់នេះជាឆ្នេរទឹករាក់សំបូរទៅដោយធនធានជីវៈចំរុះច្រើន ដូចនេះនឹងប៉ះពាល់ទៅដល់ជីវៈចំរុះទាំងនោះ។ ការអភិវឌ្ឍន៍នេះក្រុមហ៊ុនត្រូវដោះស្រាយជាមួយសហគមន៍នេសាទ ពិសេសសហគមន៍នេសាទរលួស ដោយដោះស្រាយជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តើយើងដោះស្រាយជាមួយអង្គការដែលអភិរក្សស្មៅសមុទ្រនៅតំបន់នោះយ៉ាងដូចម្តេច? ដោយឡែកបញ្ហាដាំសារាយ លោកបានពិនិត្យឃើញថាមានក្រុមហ៊ុន Star Private បានវិនិយោគដាំសារាយ4,000ហ.ត ហើយការធ្លាក់ចុះការដាំសារាយគឺបណ្តាលមកពីការបូមដីចាក់បំពេញទីតាំងកំពង់ផែដែលឆ្នាំ2005 មានប្រជាជនជាង 700 គ្រួសារ ដាំសារាយ តែឥឡូវមានការធ្លាក់ចុះច្រើន។
- លោក ចាន់ វណ្ណា ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត៖ លោកបានមានប្រសាសន៍ថា លោកស្នើសុំ មិនចូលរួមផ្តល់យោបល់លើគំរោងអភិវឌ្ឍន៍នេះទេ។

Draft

- លោក សោម វិចិត្រ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពត៖ លោកប្រធានមន្ទីរបានលើកឡើងថា មន្ទីរមានការពាក់ព័ន្ធជាមួយក្រុមហ៊ុន ដោយមន្ទីរបានយកសួយសារពីក្រុមហ៊ុនលើការបូមខ្សាច់បានចំនួន 30,000ដុល្លានៅឆ្នាំ2009។ យោងតាមការបង្ហាញពីសំណាក់ក្រុមការងារ CES ឃើញថា ក្រុមហ៊ុនមានផែនការបូមខ្សាច់រយៈពេល5ឆ្នាំ ដូចនេះមន្ទីរអាចរកចំណូលចូលជាតិបានប្រមាណ 50ម៉ឺនដុល្លា តាមរយៈការបូមខ្សាច់នេះ។ លោកសូមគាំទ្រគំរោងអភិវឌ្ឍន៍នេះទាំងស្រុង ដើម្បីបានចំណូលចូលជាតិ។

- លោក ប៉ាង ប៊ុណ្ណារដ្ឋ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តកំពត៖ លោកប្រធានមន្ទីរបានលើកឡើងថា គំរោងនេះមិនមានបញ្ហាទេ ហើយការបូមខ្សាច់នេះ លោកស្នើសុំមិនចូលរួមផ្តល់យោបល់ដូចជំនាញខាងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ឬមន្ទីរធនធានទឹក និងឧតុនិយមទេ តែលោកសំណូមពរឲ្យក្រុមហ៊ុនផ្តល់ទិន្នន័យទីតាំង ដើម្បីយកទៅបញ្ចូលក្នុងផែនទី។

- លោក អ៊ុក ឡាយ អភិបាលស្រុកទឹកឈូ៖ លោកបានលើកឡើងថាគំរោងអភិវឌ្ឍន៍នេះពុំមានបញ្ហាទេ ខាងស្រុក មានភារកិច្ចសំរបសំរួលដើម្បីឲ្យក្រុមហ៊ុនបានដំណើរការរលឿនទាន់ពេល។ លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះទាំងស្រុង ។

- លោក ស៊ុក សារ៉ាដ នាយខុទ្ទកាល័យខេត្តកំពត ជាប្រធានអង្គប្រជុំ៖ លោកប្រធានអង្គប្រជុំបានលើកឡើងថា

-ខេត្តគោរពគោលការណ៍ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការសំរេចរបស់រាជរដ្ឋាភិបាល

-ការអភិវឌ្ឍន៍តែងតែប៉ះពាល់ដែលចៀសមិនបាន តែអាចមានផលប្រយោជន៍ច្រើន

-ការបូមខ្សាច់នៅខេត្តកំពត គឺដើមឡើយចេញពីទឹកជំនន់នៅខេត្តកំពត ហើយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ឲ្យបូមខ្សាច់នៅតាមបណ្តាព្រែកនានាចេញ លុះក្រោយមកមានការបូមខ្សាច់តាមព្រែកធ្វើឲ្យកាត់បន្ថយទឹកជំនន់បានមែន ជាក់ស្តែងនៅឆ្នាំ2009 មានទឹកជំនន់តិច ហើយរយៈពេលជន់ក៏មិនយូរដែរ។

-ពាក់ព័ន្ធនឹងគំរោងអភិវឌ្ឍន៍នេះ កន្លងមកពិតជាមានបាតុភាពកើតឡើងមែន ដោយសារមានគណបក្សប្រឆាំងនៅពីក្រោយ។

-ខាងអាជ្ញាធរឃុំបានលើកឡើងហើយថាប្រជាជនពុំមានបញ្ហាទេ លោកជឿថាការអភិវឌ្ឍន៍នឹងមានការប៉ះពាល់ តែក៏មានផលចំណេញផងដែរសំរាប់ប្រជាជន និងប្រទេសជាតិ។

-ការបូមខ្សាច់សំរាប់បង្កើតឃ្លងនាវាចេញ-ចូល និងចាក់ខ្សាច់បំពេញតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពតអាចមានប្រសិទ្ធិភាពសេដ្ឋកិច្ចជាងការទុកឲ្យទឹករាក់ ព្រោះការសិក្សាបានបង្ហាញហើយថាចំណូលរបស់ប្រជាជនភាគច្រើនមានត្រឹមតែ 10,000រៀល/ថ្ងៃ ក្នុងការនេសាទ ហើយខ្លះហានដំរាក់បំណុលគេទៀត។

<u>ការបកស្រាយរបស់ម្ចាស់គំរោង៖</u>

- លោកឧកញ៉ា វិញ ហួរ ប្រធានក្រុមហ៊ុន KAMPORT PORT បានបញ្ជាក់ជូនថា:

-ក្រុមហ៊ុនទទួលបានគោលការណ៍ច្បាប់លើការវិនិយោគគំរោងនេះ

-ក្រុមហ៊ុនទទួលបានសេចក្តីសំរេចនានាលើគំរោងអភិវឌ្ឍន៍នេះហើយក្រសួងពាក់ព័ន្ធមួយចំនួនក៏បានឯកភាពដែរ

-បញ្ហាបូមខ្សាច់បង្កើតឃ្លងនាវាចេញ-ចូល គឺក្រសួងសាធារណៈការ និងដឹកជញ្ជូនបានចាត់បញ្ជូនក្រុមបច្ចេកទេសចុះសិក្សាដល់ទីតាំងជាក់ស្តែង រួចទើបក្រសួងចេញលិខិតឯកភាពលើទីតាំងឃ្លងសំរាប់នាវាចេញ-ចូលកំពង់ផែកំពត។

Draft

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើឲ្យក្រុមហ៊ុនផ្អាកសកម្មភាពមួយរយៈដោយតម្រូវឲ្យក្រុមហ៊ុនសិក្សា និងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានចប់សព្វគ្រប់សិន។

-ឥឡូវក្រុមហ៊ុនCESបានសិក្សា និងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានចប់សព្វគ្រប់ ហើយកិច្ចប្រជុំពិភាក្សាថ្ងៃនេះ គឺចង់ឲ្យមានការចូលរួមផ្តល់យោបល់ពីជំនាញពាក់ព័ន្ធថ្នាក់ខេត្ត ថាតើការសិក្សានេះ ត្រឹមត្រូវគ្រប់គ្រាន់ហើយឬនៅ? មានចំណុចណាខ្លះដែលត្រូវកែតម្រូវ?

-បញ្ហាបាត់បង់ព្រៃកោងកាង 35ហ.ត ក្រុមហ៊ុនទទួលស្គាល់ថាបាត់បង់មែន ប៉ុន្តែក្រុមហ៊ុននឹងសហការជាមួយស្ថាប័នជំនាញធ្វើការដាំកោងកាងឡើងវិញ នៅតំបន់សមស្របក្បែរកំពង់ទៅតាមលទ្ធភាពជាក់ស្តែង។

-ការប៉ះពាល់លើស្មៅសមុទ្រ ក្រសួងពាក់ព័ន្ធក៏ដឹងដែរបញ្ហានេះ។

-បញ្ហាដាំសារាយថយចុះ មិនមែនមកពីការចាក់ដីបំពេញទីតាំងកំពង់ផែទេ គឺមកពីពូជក្លាយ និងដោយសារត្រីស៊ីសារាយ គួបផ្សំនឹងការខ្វះខាតទុន ដែលជាហេតុធ្វើឲ្យពួកគាត់ឈប់ដាំសារាយ។

-តាមការសិក្សារបស់ក្រុមការងារCES ឃើញថា ការសាយភាយកករល្អក់មានត្រឹម5-6ភាគរយដល់ទីតាំងដាំសារាយ ដូចនេះទឹកអាចនឹងថ្លាវិញ។

5.3.3-ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំកោះតូច

ក្រុមការងារCES បានពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំកោះតូច នៅថ្ងៃទី01 ខែឧសភា ឆ្នាំ2010 វេលាម៉ោង09ព្រឹក នៅផ្ទះលោក នង តយ ស្ថិតនៅភូមិកណ្តាល ឃុំកោះតូច ដោយមានការចូលរួមពីសំណាក់អាជ្ញាធរភូមិ-ឃុំសរុបចំនួន48នាក់។ កិច្ចពិភាក្សានេះ គឺផ្តោតសំខាន់ទៅលើការប៉ះពាល់ ប្រជាជនដែលប្រកបមុខរបរដាំសារាយ។

នៅក្នុងកិច្ចពិភាក្សានេះ លោក សុខ សុជា ប្រធានក្រុមការងារសិក្សារបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានបានធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សា ព្រមទាំងផ្សព្វផ្សាយអំពីវត្តមានរបស់កំពង់ឲ្យប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានបានដឹង។ ក្រុមការងារបានបញ្ជាក់ជូនប្រជាជន និងអាជ្ញាធរមូលដ្ឋានយ៉ាងច្បាស់ថា ការបូមល្បាប់ខ្សាច់ បង្កើតឃ្លងនាវាសំរាប់ចាក់បំពេញតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត របស់ក្រុមហ៊ុន KAMPORT PORT នឹងធ្វើឲ្យប៉ះពាល់ដល់ការដាំសារាយក្នុងកំរិតតិចតួច ដែលក្នុងនោះការរំពឹងទុកអំពីការប៉ះពាល់ដោយសារការសាយភាយកករល្អក់មកតំបន់មានបង្គោលដាំសារាយ គឺមានកំហាប់ត្រឹម5-6%ប៉ុណ្ណោះចេញពីទីតាំងកណ្តាលនៃឃ្លងដែលត្រូវបូមក្នុងរយៈពេល1សប្តាហ៍។ បន្ទាប់មកប្រជាពលរដ្ឋនៅឃុំកោះតូចបានចូលរួមពិភាក្សា និងផ្តល់យោបល់ ដូចខាងក្រោមៈ

- លោក សេង ជី មេភូមិព្រែកចេក បានរៀបរាប់ថា ៖

-នៅក្នុងភូមិព្រែកចេកមានប្រជាជនដាំសារាយសរុបចំនួន 35គ្រួសារ ដែលកំពុងប្រកបរបរដាំសារាយ។

-ប្រជាជនមួយគ្រួសារដាំសារាយជាមធ្យម ចំនួន 50-100 ខ្សែ ដោយមួយខ្សែមានប្រវែង 60ម និងដាំចន្លោះពីបង្គោលមួយទៅបង្គោលមួយមានចំងាយ0,5ម ហើយសារាយផ្តល់ផលជាមធ្យមក្នុងមួយគ្រួសារប្រមាណ 5-15តោន/ឆ្នាំ ចំពោះសារាយសើម។

-នៅឆ្នាំ2003-2004 មានប្រជាជនដាំសារាយប្រមាណ 90ភាគរយ នៃចំនួនគ្រួសារសរុបក្នុងភូមិ (មានចំនួន 143គ្រួសារ-ទិន្នន័យឆ្នាំ2010) តែបច្ចុប្បន្នចំនួនអ្នកដាំមានការថយចុះច្រើនដោយសារៈ (1)-ដើមទុនមិនគ្រប់គ្រាន់ ប្រជាជនចំណាយលុយប្រមាណ 1,000ដុល្លា ដើម្បីដាំសារាយចំនួន 100ខ្សែ តែនៅពេលដែលផលទទួលបានតិច ដោយសារត្រីស៊ីសារាយអស់ ឬរលកបោកខ្លាំង ឬពូជសារាយមិនល្អធ្វើឲ្យសារាយអត់បានផលហើយអ្នកដាំគ្មានទុនដាំបន្តទៀតក៏ឈប់ដាំ (2)-តំលៃទីផ្សារចុះថោកៈ កន្លងមកពេលដែលសារាយកំពុងឡើងថ្លៃ (5,000រៀល/គ.ក ចំពោះសារាយស្ងួត) ឈ្មួញដើរប្រមូលទិញសារាយយកទៅលក់បន្ត តែសមត្ថកិច្ច

Draft

បានចាប់បង់ពន្ធធ្វើឲ្យសាវាយចុះថោកដល់ 3,000-4,000រៀល/គ.ក ចំពោះសាវាយស្ងួត (បច្ចុប្បន្នសាវាយសើមថ្លៃ400រៀល/គ.ក) ធ្វើឲ្យប្រជាជនមួយចំនួនឈប់ដាំ។ ជារួម លោកបានបញ្ជាក់ថា ការចាក់ខ្សាច់បំពេញទីតាំងកំពង់ផែកន្លងមកមិនប៉ះពាល់ដល់មុខរបរដាំសាវាយរបស់ប្រជាជនលោកទេ គឺដោយសារបញ្ហាដូចរៀបរាប់ខាងលើនេះ ហើយលោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះ។

☞ លោក សោម ថាន់ ប្រជាជនដាំសាវាយ នៅភូមិកណ្ដាល លោកបានមានប្រសាសន៍ថា ៖

-ក្រុមគ្រួសារលោកបានដាំសាវាយចំនួន 500ខ្សែ
-សាវាយដុះតាមធម្មជាតិ ដូចនេះការដាំសាវាយ គឺលោកដាំទៅតាមរដូវ ទៅតាមតំបន់ដែលសាវាយដុះ ជួនកាលខែនេះគាត់ដាំនៅតំបន់នេះ ហើយខែក្រោយគាត់ដាំនៅតំបន់ផ្សេងវិញ
-ប្រជាជនខ្លះឈប់ដាំដោយសារមានដើមទុនតិច ហើយពេលជួបបញ្ហាក៏ឈប់ដាំទៅ
-លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះ។

☞ លោក ព្រាប ប៊ឹម មេភូមិព្រែកអំពិល លោកបានលើកឡើងថា:

-នៅក្នុងភូមិព្រែកអំពិលមានប្រជាពលរដ្ឋដាំសាវាយសរុបចំនួន 59គ្រួសារ ស្មើនឹង 7735 ខ្សែ
-ការប្រមូលផលជាមធ្យម 40គ.ក/ខ្សែ
-ប្រជាជនអាចដាំសាវាយបានរយៈពេល6 ខែ/ឆ្នាំ គឺនៅចន្លោះខែវិច្ឆិកា-ឧសភា
-លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍នេះទាំងស្រុង ហើយលោកស្នើឲ្យគំរោងអភិវឌ្ឍន៍ឲ្យបានឆាប់រហ័ស ដើម្បីឲ្យប្រជាជនមានការងារធ្វើ និងអភិវឌ្ឍភូមិ-ឃុំ ។

☞ អ្នកស្រី តូច គឹមហៀង មុខរបរដាំសាវាយ នៅព្រែកអំពិល អ្នកស្រីបានលើកឡើងថា:

-គ្រួសារលោកស្រីដាំសាវាយចំនួន 60ខ្សែ
-ការប្រមូលផលមិនទៀងទាត់ ពេលខ្លះបានផលល្អ ពេលខ្លះត្រីស៊ីអស់សល់តែខ្សែ និងបង្គោលក៏មាន
-ក្នុងមួយរដូវមានរយៈពេល6ខែ សាវាយអាចផ្ដល់ផលប្រមាណ 2តោន
-លោកស្រីសូមគាំទ្រទៅលើគំរោងអភិវឌ្ឍន៍នេះ។

5.3.4-ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំព្រែកត្នោត

ក្រុមការងារCES បានពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅឃុំព្រែកត្នោត នៅថ្ងៃទី01 ខែឧសភា ឆ្នាំ2010 វេលាម៉ោង02និង30នាទីរសៀល នៅសាលាឃុំព្រែកត្នោត ដោយមានការចូលរួមពី សំណាក់អាជ្ញាធរភូមិ-ឃុំ និងតំណាងសហគមន៍នេសាទសរុបចំនួន 24នាក់។

☞ អ្នកស្រី ស្វាយ ថន គណនេយ្យសហគមន៍ព្រែកក្រែង និងត្រពាំងរពៅ អ្នកស្រីបានមានប្រសាសន៍ថា តាមការបង្ហាញរបស់ក្រុមការងារ CES ឃើញថា ក្រុមហ៊ុននឹងបូមខ្សាច់ចំងាយប្រមាណ 2-6គ.ម ពីដែនសហគមន៍ ដូចនេះតើការបូមខ្សាច់នៅតំបន់ទាំងនោះ អាចបណ្ដាលឲ្យបាក់ដីប៉ះពាល់ដល់តំបន់សហគមន៍របស់ពួកគាត់ដែរឬទេ? អ្នកស្រីសូមគាំទ្រការអភិវឌ្ឍន៍នេះ បើសិនក្រុមហ៊ុនបូមខ្សាច់មិនបណ្ដាលឲ្យប៉ះពាល់ដល់សហគមន៍នេសាទរបស់ពួកគាត់។ ជាមួយគ្នានេះ អ្នកស្រីស្នើសុំឲ្យមានការផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទផ្ទាល់ ដើម្បីចៀសវាងកុំឲ្យមានពាក្យថា តំណាងសហគមន៍នេសាទបានឃុបឃិតជាមួយក្រុមហ៊ុន។

Draft

- លោក សើ ឡោះ ផ្នែកអប់រំសហគមន៍ព្រែកក្រែង និងត្រពាំងរពៅ លោកបានមានប្រសាសន៍ថា៖ លោកមានការព្រួយបារម្ភខ្លាចពេលក្រុមហ៊ុនបូមខ្សាច់ទៅធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក បាត់បង់ត្រីប៉ះពាល់ដល់មុខរបរនេសាទរបស់ប្រជាជន ដូចនេះស្នើក្រុមហ៊ុនបញ្ជាក់ឲ្យច្បាស់លើចំណុចទាំងនេះ។

- លោក គី ងៀប ប្រធានសហគមន៍នេសាទ ភូមិព្រែកត្នោត លោកបានមានប្រសាសន៍ថា៖ បើក្រុមហ៊ុនបូមខ្សាច់ដើម្បីធ្វើឃ្លងនាវាចេញ-ចូលចំងាយប្រមាណ 2គ.ម ពីច្រាំងមែននោះ គឺមិនមានប៉ះពាល់ដល់សហគមន៍យើងខ្ញុំទេ ប៉ុន្តែស្នើក្រុមហ៊ុនផ្សព្វផ្សាយឲ្យប្រជាជនបានដឹងទាំងអស់គ្នាផង កុំឲ្យពួកគាត់ចោទសហគមន៍ថាសហគមន៍ផ្តិតមេ ដែលលក់ឲ្យក្រុមហ៊ុន ហើយស្នើក្រុមហ៊ុនធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់សហគមន៍។ ខ្ញុំសូមគាំទ្រគំរោងអភិវឌ្ឍន៍នេះ ដើម្បីឲ្យមានការអភិវឌ្ឍន៍រីកចំរើននៅខេត្តកំពត ក៏ដូចជាផ្តល់ការងារដល់ប្រជាជនមូលដ្ឋានផងដែរ។

- នៅក្នុងកិច្ចពិភាក្សានេះ លោក សេង ដាង អភិបាលរងស្រុកទឹកឈូក៏បានចូលរួមសំរបសំរួលផងដែរ ហើយលោកបានចូលរួមយោបល់ថា៖ យោងការសិក្សាទៅលើផ្នែកសេដ្ឋកិច្ច របស់ក្រុមហ៊ុនCES បានបង្ហាញថា GDP របស់ប្រជាជននៅឃុំព្រែកត្នោតមានចំនួន 565ដុល្លា/ឆ្នាំ/នាក់ ហើយGDP នឹងកើនឡើងបន្ថែមទៀត បន្ទាប់ពីមានវត្តមានគំរោង។ នៅកំពង់សោមគេមានកំពង់ផែស្វយ័តខេត្តព្រះសីហនុ និងកំពង់ផែកែវផុស ប៉ុន្តែនៅ ខេត្តកំពតរបស់យើងគឺគ្មាន ដូចនេះបើសិនជាមានកំពង់ផែកំពតនេះ គឺជាការល្អសំរាប់ខេត្ត និងអាចផ្តល់ការងារដល់ ប្រជាជនមូលដ្ឋាន ព្រមទាំងសេវាកម្មផ្សេងៗទៀត។ ការអភិវឌ្ឍន៍តែងតែមានការប៉ះពាល់ចៀសមិនរួច ប៉ុន្តែយើងទទួលបាននូវផលប្រយោជន៍យ៉ាងច្រើន ដូចនេះខ្ញុំសូមគាំទ្រលើគំរោងនេះ។

ជារួម នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅឃុំព្រែកត្នោត មានចំនួនប្រជាពលរដ្ឋចូលរួមចំនួន24នាក់ ក្នុងនោះប្រជាពលរដ្ឋមានការគាំទ្រលើគំរោងអភិវឌ្ឍន៍ចំនួន23នាក់ ស្មើនឹង96% ហើយប្រជាពលរដ្ឋមិនចូលរួមផ្តល់យោបល់មានចំនួន1នាក់ ស្មើនឹង4%។

5.3.5-កិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ នៅភូមិរលួស ឃុំបឹងទូក

ក្រុមការងារCES បានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅភូមិរលួស ឃុំបឹងទូក នៅថ្ងៃទី01 ខែឧសភា ឆ្នាំ 2010 វេលាម៉ោង3រសៀល នៅផ្ទះលោក ឈុន ប៊ុនលី មេភូមិរលួស ដោយមានប្រជាពលរដ្ឋចូលរួមសរុប84នាក់។

លោក ឈុន ប៊ុនលី មេភូមិរលួស លោកបានមានប្រសាសន៍ដូចតទៅ៖ កាលពីមុននៅភូមិរលួសមានសហគមន៍នេសាទដែលមានសមាជិកសរុបចំនួន182នាក់ ប៉ុន្តែឥឡូវនៅសល់ប្រមាណ40-50នាក់ប៉ុណ្ណោះ។ ការថយចុះនេះ គឺដោយសារផលនេសាទមានការថយចុះ ហើយប្រជាជនមួយចំនួនទៅធ្វើការឲ្យក្រុមហ៊ុននៅលើភ្នំបូកគោ។ លោកមេភូមិគាំទ្រលើការអភិវឌ្ឍន៍នេះទាំងស្រុង ប៉ុន្តែលោកសំណូមពរឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ឲ្យបានលឿន ដើម្បីពួកគាត់បានចូលធ្វើការងារហើយក្រុមហ៊ុនត្រូវទុកផ្លូវសំរាប់ប្រជាជនដែលអូសឈិបបានឆ្លងកាត់ដើម្បីទៅអូសឈិបផង ពីព្រោះមិនអាចដើរវាងទៅឆ្ងាយបានទេ។

លោក វីសាលន ប្រជាពលរដ្ឋនៅភូមិរលួស មានមុខរបរជាអ្នកនេសាទ លោកបានមានប្រសាសន៍ថា លោកមានការព្រួយបារម្ភខ្លាចការចាក់ខ្សាច់បំពេញទីតាំងតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពតនេះ ធ្វើឲ្យបាត់បង់ធនធានមច្ឆាជាតិ ពិសេសបាត់ទីកន្លែងរុញឈិបដែលគាត់ធ្លាប់រកពីមុនមក។ លោកមិនជំទាស់លើការអភិវឌ្ឍន៍នេះទេ ប៉ុន្តែស្នើក្រុមហ៊ុនទុកផ្លូវសំរាប់ពួកគាត់បានចេញ-ចូលអូសឈិបផង ព្រោះគាត់មិនអាចដើរវាងទៅឆ្ងាយបានទេ។ ម៉្យាងវិញទៀត លោក សំណូមពរឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ឲ្យបានលឿន ឬក៏អាចសាងសង់រោងចក្រជាមុនដើម្បីឲ្យប្រជាពលរដ្ឋបានចូលបំរើការងារ។

Draft

5.3.6-កិច្ចពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ

ក-<u>សហគមន៍នេសាទភូមិចង្ហោន</u>

កិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយសហគមន៍នេសាទភូមិចង្ហោនបានប្រព្រឹត្តទៅនៅថ្ងៃទី02 ខែឧសភា ឆ្នាំ 2010 វេលាម៉ោង៩និង30នាទីព្រឹក នៅវត្តចង្ហោន ដោយមានការចូលរួមពីសមាជិកសហគមន៍នេសាទសរុបចំនួន 53នាក់។

- លោក សុខ ជា ប្រធានសហគមន៍ចង្ហោនបានមានប្រសាសន៍ថា លោកសូមគាំទ្រលើការអភិវឌ្ឍន៍នេះ ព្រោះបើសិនកំពង់ផែត្រូវបានសាងសង់មែននោះ នឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់ខេត្ត និងប្រជាជនមូលដ្ឋាន ក៏ដូចជារួមចំណែកកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែលោកសំណូមពរឲ្យក្រុមហ៊ុនជ្រើសរើសប្រជាជននៅភូមិចង្ហោន ឃុំព្រែកត្នោត បានចូលបំរើការងារក្នុងក្រុមហ៊ុនទៅតាមសមត្ថភាពជំនាញរៀងៗខ្លួន ហើយធ្វើយ៉ាងណាកុំឲ្យបូមខ្សាច់ប៉ះពាល់ដល់សហគមន៍ពួកគាត់ ។
- អ្នកស្រី ណាវ យឿង មុខរបរនេសាទ ជាសមាជិកសហគមន៍ បានមានប្រសាសន៍ថា តើការបូមខ្សាច់របស់ក្រុមហ៊ុនអាចមានការប៉ះពាល់ដល់មច្ឆាជាតិ និងការបាក់ច្រាំងដែរឬទេ? តើវាមានផលប្រយោជន៍អ្វីខ្លះ ពីការបូមខ្សាច់បង្កើតឃ្លងនាវាចេញ-ចូលនេះ? តើក្រុមហ៊ុនជ្រើសរើសកម្មករពីភូមិចង្ហោនទៅធ្វើការអោយក្រុមហ៊ុនដែរឬទេ?
- អ្នកស្រី មូល សារ៉ន មុខរបរនេសាទ ជាសមាជិកសហគមន៍ បានមានប្រសាសន៍ថា អ្នកស្រីសូមគាំ ទ្រលើគំរោងអភិវឌ្ឍន៍នេះ ព្រោះចង់ឲ្យមានការអភិវឌ្ឍន៍ដូចនៅតំបន់ផ្សេងៗទៀត។

ខ-<u>សហគមន៍នេសាទភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ</u>

កិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយសហគមន៍នេសាទភូមិព្រែកក្រែង និងភូមិត្រពាំងរពៅបានប្រព្រឹត្តទៅនៅថ្ងៃទី02 ខែឧសភា ឆ្នាំ2010 វេលាម៉ោង1និង30នាទីរសៀល នៅវត្តត្រពាំងរពៅ ដោយមានការចូលរួមពីសមាជិកសហគមន៍សរុបចំនួន66នាក់។

- លោក ម៉ូ ម៉ុន ប្រធានសហគមន៍នេសាទភូមិព្រែកក្រែង និងភូមិត្រពាំងរពៅ បានមានប្រសាសន៍ថា លោកគាំទ្រគំរោងអភិវឌ្ឍន៍នេះ ប៉ុន្តែលោកសំណូមពរឲ្យក្រុមហ៊ុនបូមឃ្លងកុំឲ្យប៉ះពាល់ដល់ដែនសហគមន៍ ហើយស្នើឲ្យក្រុមហ៊ុនជ្រើសរើសប្រជាជនក្នុងឃុំព្រែកត្នោតចូលបំរើការជាបុគ្គលិកកម្មកររបស់ក្រុមហ៊ុនទៅតាមជំនាញរៀងៗខ្លួន និងសូមឲ្យក្រុមហ៊ុនអភិវឌ្ឍឲ្យបានឆាប់រហ័ស។
- លោក យាង ទី មុខរបរនេសាទ ជាសមាជិកសហគមន៍នៅភូមិត្រពាំងរពៅ លោកមានប្រសាសន៍ថា ស្នើឲ្យក្រុមហ៊ុនបូមឃ្លងឲ្យឆ្ងាយពីសហគមន៍របស់ពួកគាត់ ពីព្រោះខ្លាចក្លិនភក់ និងការសាយកករល្អក់ធ្វើឲ្យត្រីវត់បាត់។

គ-<u>សហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរ ភូមិព្រែកត្នោត</u>

កិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិព្រែកត្នោត បានប្រព្រឹត្តទៅនៅថ្ងៃទី02 ខែឧសភា ឆ្នាំ2010 វេលាម៉ោង3រសៀល នៅវត្តព្រែកត្នោត ដោយមានការចូលរួមពីសមាជិកសហគមន៍សរុបចំនួន65នាក់។

Draft

- លោក គី ងៀប ប្រធានសហគមន៍ បានមានប្រសាសន៍ថា ក្នុងសហគមន៍របស់លោកមានសមាជិក សរុប 142នាក់ តំណាងឲ្យ142គ្រួសារ។ លោកសូមគាំទ្រលើគំរោងអភិវឌ្ឍន៍ ពីព្រោះការអភិវឌ្ឍន៍តំបន់ សេដ្ឋកិច្ច និងកំពង់ផែកំពតនេះ នឹងជួយរួមចំណែកកាត់បន្ថយភាពក្រីក្រ ជួយអភិវឌ្ឍន៍ខេត្តពិសេសអភិវឌ្ឍន៍ មូលដ្ឋានរបស់ពួកគាត់ដែលពុំធ្លាប់មានពីមុនមក ប៉ុន្តែក្រុមហ៊ុនត្រូវធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់តំបន់សហគមន៍របស់ពួកគាត់។ លោកប្រធានក៏មានសំណូមពរដូចសហគមន៍មុនៗដែរ គឺស្នើក្រុមហ៊ុនអភិវឌ្ឍន៍ឲ្យបានឆាប់ និងយកកំលាំងពលកម្មពីភូមិរបស់គាត់ឲ្យបានចូលធ្វើការជាបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន។

- លោក យ៉ង ឈាវ មុខរបរនេសាទ សមាជិកសហគមន៍ព្រែកត្នោត លោកបានចូលរួមផ្តល់យោបល់ 4ចំណុចសំខាន់ៗគឺ៖ (ទី1)-តើក្រុមការងារចុះមកថ្ងៃនេះមកសិក្សា ឬមកបូមខ្សាច់? (ទី2)-មុននឹងគេសាងសង់កំពង់ផែ គេត្រូវសិក្សាអំពីឃ្លងនាវាជាមុនសិន តែគំរោងមានភាពផ្ទុយគ្នា។ កាលពីមុនរូបលោកធ្លាប់បានចូលរួមប្រជុំពិភាក្សាជាមួយនឹងលោក ឧកញ៉ា វិញ ហួរ ប្រធានក្រុមហ៊ុន KAMPORT PORT នេះដែរ ហើយលោកឧកញ៉ាបានបញ្ជាក់ថា ក្រុមហ៊ុននឹងចាប់ផ្តើមសាងសង់រោងចក្រឲ្យបានមុនឆ្នាំ2009 ដើម្បីស្រូបយកកំលាំងពលកម្មប្រជាជនមូលដ្ឋានចូលបំរើការងារ ប៉ុន្តែរហូតមកដល់ពេលនេះរោងចក្រនោះមិនទាន់លេចចេញចេញជារូបរាងនៅឡើយទេ។ (ទី3)-លោកមានការព្រួយបារម្ភទៅលើការបូមខ្សាច់ ពីព្រោះការបូមខ្សាច់អាចនឹងធ្វើឲ្យបាត់បង់ទ្រង់ទ្រាយដើម បាត់បង់ជំរកត្រី ក្តាម បង្កង ជាដើម។ (ទី4)-តើក្រុមហ៊ុនដែលចុះមកបូមខ្សាច់ជាក្រុមហ៊ុន KAMPORT PORT ឬ ក្រុមហ៊ុន CES?

- លោក ប៊ូ ស៊ុះ មុខរបរនេសាទ សមាជិកសហគមន៍ព្រែកត្នោត លោកបានចោទសួរ 2សំណួរគឺ តើកករទឹកដែលសាយភាយចេញពីកន្លែងបូមអាចសាយភាយបានចំងាយប៉ុន្មានគីឡូម៉ែត្រ? តើការបូមខ្សាច់ក្នុងរយៈពេល 05ឆ្នាំ អាចនឹងប៉ះពាល់អ្វីខ្លះដល់ប្រជាជន ពិសេសមុខរបរនេសាទ?

Draft

ការឆ្លើយតបរបស់ក្រុមការងារសិក្សាCES

លោក សុខ សុធា ប្រធានក្រុមការងារសិក្សា CES បានបកស្រាយចំងល់របស់សមាជិកសហគមន៍ ខាងក្រោម៖

-ទី1៖ ថ្ងៃនេះក្រុមការងារចុះមកពិគ្រោះយោបល់ មិនមែនមកបូមខ្សាច់ទេ

-ទី2៖ឃ្លងគឺក្រុមការងារបច្ចេកទេសក្រសួងសាធារណៈការ និងដឹកជញ្ជូនបានចុះសិក្សា និងបានឯកភាពលើប្លង់ឃ្លងនាវាចេញ-ចូលរួចហើយ

-ទី3៖ ការបូមឃ្លងនេះនឹងបណ្តាលឲ្យមានការប្រែប្រួលទ្រង់ទ្រាយសណ្ឋានដីតិចតួច និងប៉ះពាល់ដល់ជីវៈចំរុះមួយចំនួនក្នុងអំឡុងពេលបូមផងដែរដោយសារការសាយភាយកករល្អក់ ប៉ុន្តែការសាយភាយនេះគឺនឹងនៅសល់ត្រឹម5-6ភាគរយ ពេលកករសាយភាយចេញពីចំនុចកប៉ាល់បង្អិលខ្លួនទៅដល់ព្រំប្រទល់ដែនសហគមន៍នេសាទក្នុងរយៈពេលសប្តាហ៍។ ការបូមឃ្លងមានរយៈពេល5ឆ្នាំ ដោយចែកចេញជា4ដំណាក់កាល ដែលអាចកាត់បន្ថយបានការប៉ះពាល់ដល់គុណភាពទឹកផងដែរ។

-ទី4 ៖ ក្រុមហ៊ុនដែលត្រូវអភិវឌ្ឍន៍ និងបូមខ្សាច់ដើម្បីចាក់បំពេញទីតាំងតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត គឺក្រុមហ៊ុន KAMPORT PORT។ ដោយឡែកក្រុមហ៊ុន CES គឺជាក្រុមហ៊ុនសិក្សា និងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងបូមល្បាប់ខ្សាច់ដើម្បីបង្កើតឃ្លងនាវាចេញចូល និងការចាក់បំពេញទីតាំងតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត។

5.4-សន្និដ្ឋាន

បន្ទាប់ពីក្រុមការងាររបស់ក្រុមហ៊ុន CES បានធ្វើការស្ទង់មតិទៅលើប្រជាពលរដ្ឋចំនួន9ភូមិ ក្នុងឃុំ បឹងទូក ឃុំកោះតូច និងឃុំព្រៃកន្ធោត ស្រុកទឹកឈូ ខេត្តកំពត ដូចមានបញ្ជាក់លំអិតនៅក្នុងជំពូកទី4ស្រាប់ និងធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្ត-ស្រុក-ឃុំ និងតំណាងមន្ទីរជំនាញពាក់ព័ន្ធនៅខេត្តកំពត ព្រមទាំងធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដាំសារាយនៅភូមិព្រៃកចេក ភូមិកណ្តាល និងភូមិព្រៃកអំពិល ឃុំកោះតូច ធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិព្រៃកន្ធោត និងសហគមន៍នេសាទភូមិចង្ហោន និងសហគមន៍នេសាទព្រៃក្រែង និងត្រពាំងរពៅបានបង្ហាញលទ្ធផលដូចតទៅ ៖

-លទ្ធផលនៃការស្ទង់មតិរបស់ប្រជាពលរដ្ឋចំនួន215នាក់(215គ្រួសារ) ដែលបានផ្តល់សម្ភាសន៍មានការគាំទ្រលើគំរោងអភិវឌ្ឍន៍ចំនួន176នាក់ ស្មើនឹង82% មិនគាំទ្រលើគំរោងអភិវឌ្ឍន៍ចំនួន22នាក់ ស្មើនឹង10% និងមិនមានយោបល់ក្នុងការផ្តល់សម្ភាសន៍មានចំនួន17នាក់ ស្មើនឹង8%។

-ការពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្ត-ស្រុក-ឃុំ និងតំណាងមន្ទីរជំនាញពាក់ព័ន្ធនៅខេត្តកំពតមានការ គាំទ្រលើគំរោងអភិវឌ្ឍន៍នេះ លើកលែងតែមន្ទីរធនធានទឹក និងឧតុនិយមមិនចូលរួមផ្តល់យោបល់ និង រដ្ឋបាលជលផលកំពតបានលើកឡើងអំពីការប៉ះពាល់ដល់ស្មៅសមុទ្រដែលត្រូវអភិរក្ស។

-ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅភូមិរលួស ឃុំបឹងទូកមិនមានការជំទាស់ទៅនឹងគំរោងអភិវឌ្ឍន៍នេះទេ ប៉ុន្តែប្រជាពលរដ្ឋបានសំណូមពរ ៖

- ✓ ស្នើសុំឲ្យក្រុមហ៊ុនផ្តល់លទ្ធភាពដល់ពួកគាត់ឲ្យចូលបំរើការងារក្នុងគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន
- ✓ ជួយអភិវឌ្ឍន៍ភូមិ-ឃុំរបស់ពួកគាត់ ដែលក្នុងនោះមានទឹកស្អាត អគ្គិសនី ផ្លូវថ្នល់ សាលារៀន
- ✓ ជួយធ្វើទំនប់ទប់ទឹកប្រៃកុំឲ្យទឹកសមុទ្រចូលដីស្រែរបស់ពួកគាត់
- ✓ ស្នើសុំឲ្យក្រុមហ៊ុនជួយស្តារប្រឡាយឲ្យបានជ្រៅ និងធំបន្តិច ដើម្បីផ្តល់ភាពងាយស្រួលដល់ការ ចតទូក
- ✓ ទុកផ្លូវទឹកឲ្យប្រជាជនចេញទៅធ្វើការនេសាទ និងអូសឈិប
- ✓ សុំឲ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍ឲ្យបានឆាប់រហ័ស។

ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដាំសារាយនៅភូមិព្រៃកចេក ភូមិកណ្តាល និងភូមិព្រៃកអំពិល ឃុំកោះតូច មិនជំទាស់ទៅនឹងគំរោងអភិវឌ្ឍន៍នេះទេ។ យោងទៅតាមការពិគ្រោះយោបល់សាធារណៈ(ចំពោះអ្នកដាំសារាយដែលមកចូលរួម) និងការសាកសួររបស់មេភូមិ(ចំពោះអ្នកដាំសារាយផ្សេងទៀតដែលមិនបានចូលរួមក្នុងការពិគ្រោះយោបល់សាធារណៈ)បានឲ្យដឹងថា បច្ចុប្បន្ន ប្រជាពលរដ្ឋទាំងបីភូមិកំពុងប្រកបមុខរបរដាំសារាយនៅ ៖

☞ ភូបិព្រៃកចេកមានចំនួន 34គ្រួសារ ដាំសារាយដែលមានចំនួន 4,970ខ្សែ (1ខ្សែ= 50ម ឬ 60ម) ឬគិតជាមធ្យមស្មើនឹង17,39ហិកតា ហើយទទួលបានទិន្នផលសរុប261តោន/ឆ្នាំ

☞ ភូមិកណ្តាលមានចំនួន 63គ្រួសារ ដាំសារាយដែលមានចំនួន 8,670ខ្សែ (1ខ្សែ= 60ម ឬ 70ម) ឬគិតជាមធ្យមស្មើនឹង 28,18ហិកតា ហើយទទួលបានទិន្នផលសរុប614 តោន/ឆ្នាំ

☞ ភូមិព្រៃកអំពិលមានចំនួន59គ្រួសារ ដាំសារាយដែលមានចំនួន 7735ខ្សែ (1ខ្សែ= 50ម-60ម) ឬគិតជាមធ្យមស្មើនឹង 21,27ហិកតា ហើយទទួលបានទិន្នផលសរុប 355.5តោន/ឆ្នាំ

☞ ជារួម បច្ចុប្បន្ននេះការដាំសារាយរបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះ បើប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំ2002។ យោងទៅលើទិន្នន័យនៃការសិក្សារបស់ក្រុមការងារបានបង្ហាញឲ្យឃើញថា ផ្ទៃដីដាំដុះរបស់ប្រជាពលរដ្ឋក្នុងភូមិព្រៃកចេក ភូមិកណ្តាល និងភូមិព្រៃកអំពិល ឃុំកោះតូច គិតជាមធ្យម នៅសល់តែ 67ហិកតា ប៉ុណ្ណោះ។ លើសពីនេះ

Draft

ទៅទៀត ប្រជាពលរដ្ឋដាំសាកាយបានសំណូមពរដល់ក្រុមហ៊ុនបូមខ្សាច់ដើម្បីបង្កើតឃ្លងនាវាមិនធ្វើឲ្យប៉ះពាល់ដល់ការដាំសាកាយ និងផ្តល់លទ្ធភាពដល់ ពួកគាត់ចូលបំរើការងារនៅក្នុងក្រុមហ៊ុនទៅតាមជំនាញរបស់ពួកគេ។

ការពិគ្រោះយោបល់ជាមួយសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរភូមិព្រែកត្នោត និងសហគមន៍នេសាទភូមិចង្ហោន និងសហគមន៍នេសាទព្រែកក្រែង និងត្រពាំងរពៅ ដែលប្រជាពលរដ្ឋភាគច្រើនមិនជំទាស់ទៅនឹងគំរោងបូមខ្សាច់នេះទេ ក៏ប៉ុន្តែប្រជាពលរដ្ឋបានសំណូមពរ ៖

- ✓ ស្នើសុំឲ្យក្រុមហ៊ុនផ្តល់លទ្ធភាពដល់ពួកគាត់ឲ្យចូលបំរើការងារក្នុងគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន
- ✓ ជួយអភិវឌ្ឍន៍ភូមិ-ឃុំរបស់ពួកគាត់ ដែលក្នុងនោះមានទឹកស្អាត អគ្គិសនី ផ្លូវថ្នល់ សាលារៀន
- ✓ ទុកផ្លូវទឹកឲ្យប្រជាជនចេញទៅធ្វើការនេសាទ
- ✓ សុំឲ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍ឲ្យបានឆាប់រហ័ស
- ✓ សុំកុំឲ្យក្រុមហ៊ុនបូមល្បាប់ខ្សាច់បង្កើតឃ្លងនាវាចេញ-ចូលប៉ះពាល់ដល់ការនេសាទ និងដែនសហគមន៍របស់ពួកគាត់
- ✓ ស្នើសុំឲ្យក្រុមហ៊ុនបូមល្បាប់ខ្សាច់ដោយអនុវត្តទៅតាមផែនការឲ្យបានច្បាស់លាស់។

Draft